**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសគីរីសាគរ កោះកុង

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្ដីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា-អភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្ដីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ ស្ដីពីការកែសម្រួលលើមាត្រា ៤ ចំណុច ៤.១ និងចំណុច ៤.៣ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**សម្រេច**

**មាត្រា១** : បង្កើត **តំបន់សេដ្ឋកិច្ចពិសេសគិរីសាគរ កោះកុង** ( KIRISAKOR KOH KONG S E Z ) ដែលមានទីតាំងស្ថិតនៅ**ឃុំព្រែកខ្សាច់ និងឃុំភ្ញីមាស ស្រុកគិរីសាគរ និងឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង** ។

**មាត្រា២** : **តំបន់សេដ្ឋកិច្ចពិសេសគិរីសាគរ កោះកុង** ផ្នែក ក និង ខ មានទំហំ ពីរពាន់ ពីររយ ហិកតា និងហុកសិបប្រាំ អា ដូចមានប្លង់ទីតាំងព្រំប្រទល់ភូមិសាស្ត្រ ក្នុងឧបសម្ព័ន្ធដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ ។

**មាត្រា៣** : ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេសគិរីសាគរ កោះកុង** ដូចមានកំណត់ក្នុងមាត្រា២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន ។

**មាត្រា៤** : ការរៀបចំ និងការប្រព្រឹត្តទៅនៃតំបន់សេដ្ឋកិច្ចពិសេសនេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានា នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តកោះកុង និងក្រុមហ៊ុន កោះកុង អេស អ៊ី ហ្សិត ខូ អិលធីឌី ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសូមចុះហត្ថលេខា
អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

សុខ ចិន្តា

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា៥
- ឯកសារ-កាលប្បវត្តិ




តារាងនិយាមការនៃចំណុចព្រំដី

Projection UTM, Zone 48N, Datum WGS 84.

| Points_ID | Northing (m) | Easting (m) | Points_ID | Northing (m) | Easting (m) |
|---|---|---|---|---|---|
| ផ្នែក ក | | | 33 | 1243809.004 | 293630.192 |
| 1 | 1241490.328 | 289709.238 | 34 | 1243960.442 | 293687.248 |
| 2 | 1241275.470 | 288803.957 | 35 | 1243724.305 | 294551.035 |
| 3 | 1240769.432 | 288035.830 | 36 | 1243430.088 | 295157.300 |
| 4 | 1240823.134 | 287376.199 | 37 | 1243258.233 | 295724.187 |
| 5 | 1241374.673 | 286687.171 | 38 | 1243222.459 | 296528.990 |
| 6 | 1241466.241 | 287010.439 | 39 | 1243328.465 | 295618.101 |
| 7 | 1242128.801 | 287375.369 | 40 | 1238640.860 | 295736.545 |
| 8 | 1242001.683 | 287439.723 | 41 | 1238650.679 | 295388.438 |
| 9 | 1242063.298 | 287679.110 | 42 | 1238977.114 | 296115.521 |
| 10 | 1242071.745 | 287764.338 | 43 | 1239256.194 | 295130.211 |
| 11 | 1242459.578 | 287706.546 | 44 | 1239406.468 | 295209.164 |
| 12 | 1242787.035 | 288581.463 | 45 | 1239835.296 | 294741.091 |
| 13 | 1242920.193 | 288743.703 | 46 | 1239934.073 | 294463.085 |
| 14 | 1242908.760 | 288922.074 | 47 | 1240072.622 | 294250.519 |
| 15 | 1242980.992 | 289065.678 | 48 | 1240163.848 | 293874.898 |
| 16 | 1242878.869 | 289399.013 | 49 | 1240167.368 | 293799.075 |
| 17 | 1242868.433 | 289390.550 | 50 | 1240158.166 | 293497.807 |
| 18 | 1242717.628 | 289678.526 | 51 | 1240131.111 | 293128.875 |
| 19 | 1242527.036 | 289853.034 | 52 | 1240115.097 | 292423.158 |
| 20 | 1242007.621 | 289658.873 | 53 | 1241146.166 | 291184.838 |
| ផ្នែក ខ | | | ផ្នែក គ | | |
| 21 | 1242009.182 | 289686.869 | 39 | 1243328.465 | 295618.101 |
| 22 | 1242532.915 | 289683.002 | 54 | 1244267.430 | 296442.411 |
| 23 | 1242738.025 | 289801.467 | 55 | 1243012.412 | 296950.433 |
| 24 | 1242865.919 | 289441.281 | 56 | 1241792.856 | 311892.927 |
| 25 | 1242796.230 | 289668.752 | 57 | 1235990.370 | 312368.125 |
| 26 | 1242877.828 | 289853.129 | 58 | 1235990.368 | 301192.429 |
| 27 | 1243646.322 | 291934.406 | 59 | 1237531.709 | 300139.387 |
| 28 | 1243888.523 | 292432.227 | 60 | 1237865.742 | 299415.400 |
| 29 | 1243291.895 | 292825.854 | 61 | 1236131.184 | 298375.062 |
| 30 | 1243238.402 | 293436.577 | 62 | 1237932.892 | 298097.360 |
| 31 | 1243412.257 | 293387.541 | 40 | 1238640.860 | 295736.545 |
| 32 | 1243657.438 | 293391.999 | | | |

បានពិនិត្យ និង ឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៨
ប្រធាននាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ

លឹម វ៉ាន់

បា:
ភ្នំពេញ.ថ្ងៃទី ·
ប្រធា:




ត្រឹមត្រូវ
ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៨
បកដ្ឋានបច្ចេកទេស

ឡា ដាខុឌ

ភ្នំពេញ,ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៨
ប្រធានក្រុមវាស់វែង

ណុប សោភណ្ឌ